ឧបសៅសង្ហា

# ហេតុអ្វី សម្លាប់ ?



កុមារយោធាខ្មែរក្រហម

# សាកល្បងពិចារណា អំពី ឧក្រិដ្ឋកម្ម នៃបក្សកុម្មុយនិស្តខ្មែរ

## មាតិការឿង

**សេចក្តីផ្តើម**........................................2
**ហេតុផល នៃ ឆ្កួតយស**..............................7
**សេចក្តីសន្និដ្ឋាន**...................................19

# សេចក្ដីផ្ដើម

បួនទសវត្សរ៍ បានកន្លងផុតមកហើយ, អតីតកាល នៃ របបខ្មែរក្រហម នៅតែជា ចំណុចសួរ ដល់ប្រជាជាតិខ្មែរ ថា ហេតុអ្វីបានជាមានកើត នូវការសម្លាប់មហាជន ដោយខ្លួនឯង នៅក្នុងប្រទេស អះអាងថាជាទីជម្រង នៃ ពុទ្ធសាសនា ? គេអាចទំលាក់កំហុសដល់ លទ្ធិកុម្មុយនិស្ត ដែលអង្គការលើ យកមកអនុវត្ត ព្រោះលទ្ធិនេះ បាន បង្ហាញ នូវភាពសាហាវឃោរឃៅ របស់ខ្លួន លើលោកនេះ។ គេអាចនិយាយបានថា « ប្រវត្តិសាស្ត្រ នៃលទ្ធិកុម្មុយនិស្ត គឺជាអន្តរាយ នៃមនុស្សលោក »។ វាជាបាតុភូតដ៏សំខាន់ មួយ ក្នុងសតវត្សទី២០ ដែលចាំផ្ដើមឡើង ពីឆ្នាំ ១៩១៤ និងបញ្ចប់នៅទីក្រុងម៉ូស្គូ ក្នុងឆ្នាំ ១៩៩១។ ដូច្នេះ គេអាច សួរជាសំនួរថា លទ្ធិកុម្មុយនិស្ត ជាអ្វី ? ពួកអ្នកវិទូ នយោបាយខ្លះ គេ បែងចែកលទ្ធិនេះ រវាង ទ្រឹស្ដី និង ការ អនុវត្តន៍។ ជា ទស្សនៈវិជ្ជា នយោបាយ, លទ្ធិនេះ វា មាន យូរយាមកហើយ, តាំងពីរាប់ពាន់ឆ្នាំមកម្លេះ, ដែល លោក Platon បានសរសេរនៅក្នុងសៀវភៅ របស់លោក មានចំណងជើងថា « សារធារណរដ្ឋ »។ រហូតមានអ្នកខ្លះ យល់ឃើញ នៅក្នុង សិក្ខាបទ នៃព្រះពុទ្ធ ក៏ឃើញមាន វត្ថុ ធាតុ នៃលទ្ធិនេះដែរ។ ព្រោះថា នៅក្នុងទ្រឹស្ដី នៃ លទ្ធិ កុម្មុយនិស្ត វាមាន វិធីសាស្ត្រ និមិត្តសញ្ញា (utopique)

ដែលហាក់បីដូចជា អាចយកមកធ្វើជា ឧបករណ៍ សំរាប់រិះគន់ ដល់បញ្ហាសង្គមបាន។ ទ្រឹស្តីនេះ ចូលរួមក្នុងកិច្ចពិភាក្សា នៃគំនិត ដែលផ្តល់ខ្យល់ អុកស៊ីហ្សែន ដល់ លទ្ធិប្រជាធិបតេយ្យ។ តែ ការអនុវត្តន៏ នៃលិទ្ធិកុម្មុយនិស្ត វាខុសឆ្ងាយពីទ្រឹស្តី របស់វា នៅក្នុងទីកន្លែងមួយ ក្នុង រយៈពេលមួយ ដូចយ៉ាងនៅប្រទេស រុស្ស៊ី, គុយបា, ចិន, យៀកណាម...ដឹកនាំដោយ ជនដ៏ល្បីល្បាញ ដូចយ៉ាងលោក ស្តាលីន, ម៉ៅ សេងទុង, ហូ ជីមិញ, កាស្ត្រូ។ គឺក្នុងប្រទេសទាំងឡាយនោះឯង ដែលមាន ការបង្រ្កាបជាប្រព័ន្ធ រហូតដល់កំរិតដ៏អស្ចារ្យមួយ គឺ ប្រព្រឹត្តិ នូវ ភេរវកម្ម នៅក្នុងរបៀបដឹកនាំ នៃរដ្ឋាភិបាល។ វាហួសពីឧក្រិដ្ឋកម្ម ទៅលើបុគ្គល, ការសម្លាប់រង្គាលយ៉ាងទៀងទាត់ ដើម្បី អំណាច, លទ្ធិកុម្មុយនិស្ត បានបង្កើត នូវរបបដឹកនាំមួយ សំរាប់ប្រព្រឹត្តិ នូវឧក្រិដ្ឋកម្មមហាជន តែម្តង។ តែ របបឃោរឃៅនេះ នៅក្នុងរយៈពេលដ៏យូរអង្វែងមួយ មិនដែលមាននរណាលើកយកមក សិក្សា និង វាយតម្លៃ តាមទស្សនៈពី ប្រវត្តិសាស្ត្រ ដល់ សីលធម៏ នោះឡើយ ព្រោះថា របបនេះ បានចូលរួមប្រយុទ្ធប្រឆាំងនឹង របបណាស៊ី នៅក្នុងសង្រ្គាមលោកទី២។ បន្ទាប់មក មិនសូវមាននរណា មានសេចក្តីក្លាហ៊ាន ធ្វើការប្រៀបធៀប រវាង ឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្ត ដោយរបបណាស៊ី និង កុម្មុយនិស្ត។ វាហាក់បីដូចជា ទុក ឧក្រិដ្ឋកម្ម កុម្មុយនិស្ត ជា អំពើធម្មតា។

មិនតែប៉ុណ្ណោះ មានបញ្ញាវន្ត ល្បីល្បាញ ជាច្រើននៅក្នុងពិភពលោក បានចូលជាសមាជិក នៃគណបក្សកុម្មុនិស្ត ហាក់បីដូចជាទុក បក្សនេះ ជា ដំណោះស្រាយដាច់ខាតនៃបញ្ហាសង្គម។ ដូចអ្នកនិពន្ធបារាំងសែសល្បីល្បាញម្នាក់ឈ្មោះ Aragon លោកសរសេរថា « នេត្រាខៀវ នៃបដិវត្តន៍ ដែលចែងចាំ នូវភាពឃោរឃៅ ជាការចាំបាច់មួយ[1] »។

ដូច្នេះ លទ្ធិកុម្មុយនិស្ត នៅទស្សវត្សរ៍ ៥០-៦០-៧០ បានក្លាយជានិមិត្ត នៃការតស៊ូ នៃប្រទេសអាណានិគម និងប្រជាពលរដ្ឋ ដែលត្រូវបានគេជិះជាន់។

នៅស្រុកខ្មែរក្នុងអំឡុងពេលដ៏រុងរឿង នៃលទ្ធិកុម្មុយនិស្ត លើពិភពលោក, លទ្ធិនេះ មិនមានឥទ្ធិពល គួរអោយកត់សំគាល់ លើប្រជាពលរដ្ឋខ្មែរនោះទេ។ ជាការពិត, វាមានបក្សកុម្មុនិស្តខ្មែរ ដឹកនាំដោយជនយួនម្នាក់ បន្លំធ្វើជាខ្មែរ ឈ្មោះ សឺន ង៉ុកមិញ, ប៉ុន្តែបក្សនេះ វាគ្រាន់តែផ្នែកមួយ នៃ បក្សកុម្មុយនិស្តឥណ្ឌូចិន ដែលមានយួនជាអ្នកដឹកនាំតាំងពីឆ្នាំ ១៩៣០ មកម្លេះ។ តែនៅឆ្នាំ ១៩៥១ នៅក្នុងយុទ្ធសាស្ត្រយួន ក្រុមតស៊ូ ខ្មែរកុម្មុយនិស្ត ប្រឆាំងអាណានិគមបារាំង បានបង្កើត គណបក្សមួយ បែកចេញពី ចលនាតស៊ូខ្មែរឥស្សរៈ មានឈ្មោះថា « បក្សប្រជាជនបដិវត្តកម្ពុជា »។ បក្សនេះស្ថិតនៅក្រោមការត្រួតត្រា

---

[1] Les yeux bleus de la révolution brillent d’une cruauté nécessaire.

យួនដដែល។ ក្រោយពេលស្រុកខ្មែរ បានឯករាជ្យ, បក្ស នេះ មកចូលរួម ក្នុងសង្គមជាតិវិញ ឯអ្នកខ្លះទៀត ក៏នាំគ្នាទៅហាណូយ តាមយួនយៀកមិញ និងខ្លះទៀត ត្រូវរស់នៅតាម ជាយដែនខ្មែរ-យួន ដោយមាន ជំនួយពីយួនកុម្មុយនិស្ត។

នៅឆ្នាំ ១៩៦០ ពួកនិន្នាការកុម្មុយនិស្តមួយទៀត ហៅថា ខ្មែរក្រហម បានបង្កើត « បក្សកុម្មុយនិស្តកម្ពុជា » មាននិន្នាការ ទៅរកចិនកុម្មុយនិស្ត។ បក្សនេះ ធ្វើសកម្មភាព នៅក្នុងការលាក់បាំង ប្រឆាំងនឹង សីហនុ តែគាំទ្រ ដោយគ្មានលាក់លៀម នូវការតស៊ូ នៃយួនកុម្មុយនិស្ត នៅយៀកណាមខាងត្បូង ដូចសីហនុដែរ។ នៅឆ្នាំ ១៩៧០, សម្តេច សីហនុ ត្រូវសភាជាតិខ្មែរ ទំលាក់ទ្រង់ ពីមុខតំណែង។ ប្រតិកម្ម របស់ព្រះអង្គ គឺទ្រង់ សូមអោយទ័ពយៀកកុងតាំងទ័ពនៅស្រុក វាយប្រហារកងទ័ពជាតិខ្មែរ ដើម្បី ជួយព្រះអង្គ ត្រឡប់មកកាន់អំណាចវិញ។ ខណៈពេលនោះដែរ តាមសំណើរ ប៉េកាំង និង ហាណូយ, ទ្រង់បង្កើត រណសិរ្ស បង្រួបបង្រួមជាតិមួយ ដើម្បី រួមច្បាំង ជាមួយពួកយៀកកុង ដើម្បី ប្រលំ របបសាធារណរដ្ឋខ្មែរ។ រណសិរ្សនោះ គឺជាការរួបរួម នៃ បក្សកុម្មុយនិស្តកម្ពុជា ដឹកនាំដោយ ប៉ុល ពត, បក្សប្រជាជនបដិវត្តកម្ពុជា ដឹកនាំដោយពួកយួនកុម្មុយនិស្ត និង ពួកសីហនុនិយម មួយចំនួនតូចគ្មានមេដឹកនាំច្បាស់លាស់។ ត្រូវដឹងថា សម្តេច សីហនុ

ទ្រង់ យកការគាំគួន និង កំហឹង ជាត្រីមុខ រាជំរុញទ្រង់ អោយ ប្រញាប់ប្រញាល់ ចូលរួមជាមួយ ពួកកុម្មុយនិស្ត ដោយមិនបានគិតពិចារណា អោយបានច្បាស់លាស់សិន ដើម្បីថ្លឹង រកប្រយោជន៍ជាតិ។ ការណ៍នេះ នាំអោយព្រះអង្គ បាត់នូវការគាំទ្រ ពីសំណាក់ប្រជាជនខ្មែរ មួយភាគធំ។ មួយវិញទៀត ព្រះអង្គគ្មានអំណាចអ្វីបន្តិចសោះឡើយ នៅក្នុងជួរ រណសិរ្សនោះ ព្រោះជារណសិរ្ស របស់ពួកកុម្មុយនិស្ត ដែលជា សត្រូវចាស់នឹងព្រះអង្គ។ នៅឆ្នាំ ១៩៧៥, នៅក្នុង បរិបទអន្តរជាតិ ដែលជាសុភស្លានភាព ដល់ ចិន និង យួន កុម្មុយនិស្ត គឺ ការដកថយអាមេរិកាំងចេញពីសង្គ្រាម នៅស្រុកយួនខាងត្បូង ក្នុងក្របខណ្ឌ នៃកិច្ចព្រមព្រៀងសន្តិភាព នៅឆ្នាំ ១៩៧៣។ ទិន្នការណ៍ថ្មីនេះ តម្រូវអោយ សហរដ្ឋអាមេរិក កាត់ជំនួយយោធា ដល់ របបសាធារណរដ្ឋខ្មែរ ដែលកំពុងច្បាំង តទល់នឹង ទ័ពកុម្មុយនិស្ត ខ្មែរ-យួន, វានាំអោយ ពួកនោះ មានប្រៀបលើ កងទ័ពជាតិខ្មែរ។ នៅក្នុងស្ថានភាព ដ៏ពិបាកពន្យល់, កងទ័ពជាតិខ្មែរ បានដាក់អាវុធ នៅក្នុងសេចក្តីសង្ឃឹមថាមាន ការបង្រួបបង្រួមជាតិ ដើម្បី សន្តិភាព។ តែពួកខ្មែរក្រហម ចាប់យក ស្ថានភាពនេះ ដើម្បីប្រកាស នូវជ័យជំនះ ដោយអាវុធ របស់ខ្លួន។ ហើយអំណាចទាំងឡាយបាន ធ្លាក់ទៅក្នុងកណ្តាប់ដៃ ក្រុមគ្រួសារ ប៉ុល ពត ដែលមាន ឈ្មោះថា អង្គការលើ ដែលនៅក្នុងនោះមាន ប៉ុល ពត,

ខៀវ ប៉ុណ្ណារី (ភរិយា ប៉ុល ពត), អៀង សារី, ខៀវ ធីរិទ្ធ (ភរិយា អៀង សារី)។ គ្រួសារនេះ បានបោសសំអាតមនុស្ស ដែលប្រឆាំងនឹងខ្លួន រួចបំផ្លាញខ្មែរ ស្ទើរតែអស់មនុស្ស រលីងពីស្រុកខ្មែរ ក្នុងរយៈពេលដ៏ខ្លីមួយ។ សកម្មភាពអង្គការនេះ បានក្លាយទៅជា ខ្នាំងស៊ីរូងផ្ទៃក្នុង បំបាត់ពូជសាសន៍ខ្មែរ ដើម្បីផ្តល់ផលប្រយោជន៍ អោយយួន តែម្តង។

## ហេតុផល នៃ ឆ្កួតយស

ហេតុផល នៃឆ្កួតយស របស់អង្គការលើខ្មែរក្រហម គឺជាចំណុច នៃជំនួប នៃទំហំបីយ៉ាង ចាក់ឬស នៅក្នុងបរិបទភូមិសាស្ត្រ និង នៅក្នុងពេលវេលាមួយជាក់លាក់។ ទំហំ ឆ្កួតយស របស់ប៉ុល ពត, ទំហំ នៃប្រវត្តិសាស្ត្រជាតិខ្មែរ និង ទំហំ នៃឥទ្ធិពល របស់លទ្ធិកុម្មុយនិស្តអន្តរជាតិ ជាពិសេស កុម្មុយនិស្តអាស៊ី។

### ទំហំ ឆ្កួតយស ប៉ុល ពត

ទោះបី អង្គការលើ ខំឃោសនាជាផ្លូវការថា « បដិវត្តន៍ខ្មែរ មិនដែលមានឡើយនៅក្នុងលោកនេះ ឬ បដិវត្តន៍មានតែមួយ »។ តែបើពិនិត្យបន្តិច វាមានក្លិនផ្សរ ដូចជាអាត្មានិយម[2] (dolorisme) ខ្លាំងក្លា ឬ គំនំឈឺចាប់ ជាការ

[2] លទ្ធិដែលប្រកាន់ថាការឈឺចាប់មានប្រយោជន៍។

សងសឹក និង បំណង ធំខុសខ្នាត។ អ្នកបដិវត្តន៍ ត្រូវមាន ការឈឺចាប់សែនទ្វី ចំពោះអំពើរបស់សត្រូវ និង ចំពោះ មុខ នៃអយុត្តិធម៌ ព្រោះវានាំអោយមាន សេចក្តីប្តេជ្ញា ចិត្ត បំរើ បក្ស គ្មានលំអៀង។ ដូច្នេះ ការឈឺចាប់ ខ្លាំងក្លា វាជាប្រយោជន៍បក្ស។ បក្ស ជាអ្នកបោសសំអាត សង្គម ចាស់ ហើយ វាយបំបាក់ វណ្ណៈ អោយរលាយសូន្យ ដើម្បី កសាង សង្គមថ្មី ដ៏ផូរផង់មួយ ដែលជា គំរូ សំរាប់ពិភព លោក។ ជាសង្គមកុម្មុយនិស្ត បរិសុទ្ធ សូម្បី ប្រទេសចិន ប្រជាមានិត ក៏ចង់ធ្វើតាមខ្មែរដែរ។ ទំហំ នៃអាត្មុរនិយម ខ្លាំងក្លា និង បំណងហួសហេតុ នេះ ជា ការស្រម័យ របស់ ប៉ុល ពត ដែលទុកជាឆ្កួតយសមួយ ដែលនាំអោយប្រជា ជាតិខ្មែរ ធ្លាក់ក្នុងរន្ធដៅខ្មោចទាំងរស់។

## ទំហំ នៃប្រវត្តិសាស្ត្រជាតិខ្មែរ

ស្រុកខ្មែរ ធ្លាប់ជាស្រុកសម្បូណ៌សប្បាយ, មានទេពធីតាជា អ្នកថែរក្សា, មានអតិតកាល ដ៏រុងរឿងសម្បើម។ ប៉ុន្តែ ស្ថានភាព នៃកិត្តិគុណនេះ វាចប់បាត់ទៅហើយ តាំងពី សតវត្សទី១៥មក។ ស្រុកខ្មែរ ក្លាយជាប្រទេសតូច រស់នៅ ក្នុងទុក្ខវេទនា គ្មានសេចក្តីថ្លៃថ្នូរ ហើយ ស្ថិតនៅក្រោម ការត្រួតត្រា នៃប្រទេសជិតខាង។ ពួកអ្នកដឹកនាំ បង្កើត ជាបក្សពួក ប្រឆាំងគ្នា ដើម្បីដណ្តើមអំណាចគ្នា ហើយ តែងតែ ទៅពឹងពាក់បរទេស ឲជួយខ្លួន ដោយប្តូរនឹង ប្រយោជន៍ជាតិ។ ក្នុងទសវត្សរ៍ ៦០ ស្រុកខ្មែរ ឧកខាន

នូវការហោះឡើង នៃអភិវឌ្ឍសេដ្ឋកិច្ច ដោយសារ ជម្រើស យក នយោបាយសេដ្ឋកិច្ចបិទទ្វារ ដែលនាំឲស្រុក ក្លាយជា ស្រុកខ្សោយ មាន ប្រជាពលរដ្ឋភាគច្រើន រស់ក្នុងភាពក្រលំបាក។ ដូច្នេះ ស្រុកខ្មែរ ជា « តំណខ្សោយ » ទាំងវិស័យ សេដ្ឋកិច្ច ក៏ដូចវិស័យនយោបាយ នៅក្នុង បរិស្ថាន ដំបន់ និង អន្តរជាតិ, ជាពិសេស នៅក្បែរ សង្គ្រាមយៀកណាម។ អ្នកខ្លះ យល់ឃើញថា ទម្ងន់ នៃប្រវត្តិសាស្ត្រនេះឯង ដែល បង្កើត នូវលក្ខណៈសម្បត្តិ នៃជាតិខ្មែរ ដែលវាជួយរុញ នូវ សកម្មភាពឃាតកម្ម នៃពួកខ្មែរក្រហម នៅក្នុងគំនិត សងសឹក។ ចំណែក ពុទ្ធសាសនា តាំងពីបូរាណកាល មក ដល់ បច្ចុប្បន្នកាល គ្មានការវិវត្ត ជាវិជ្ជមាន ក្នុងតួនាទី មួយ ច្បាស់លាស់ នៅក្នុងសង្គម : ការប្រដើយកន្តើយ របស់ពុទ្ធសាសនា ចំពោះបញ្ហាសង្គម និង ការទាក់ទងទៅ នឹងអត្តភាព នៃ អនាគត នៃការចែក បុណ្យ និង បាប ក្នុងជីវិតបច្ចុប្បន្ន វាផ្ទុយគ្នាស្រឡះនឹង ជីវិតរស់នៅ របស់ មនុស្ស និង ទស្សនវិស័យ នៃបដិវត្តន៍សង្គម។ តែ ប្រតិបុគ្គលនិយម (anti-individualisme) វិញ វាដូចគ្នានឹង ទស្សនៈ នៃអង្គការ គឺ ការរំលាយ « ខ្ញុំ »។ ជាការពិតហើយ, ពុទ្ធសាសនា ត្រូវបានរបបខ្មែរក្រហម បង្រាបដោយហិង្សា យ៉ាងណាក្តី ក៏មិនដែលបង្កើត នូវទំនប់ទប់នឹង អំពើអសីលធម៌នោះដែរ។ មួយវិញទៀត, ទស្សនៈ នៃព្រហ្មលិខិត « បុណ្យ-បាប » អប់រំដោយពុទ្ធសាសនា វាជ្រាបក្នុងចិត្ត

គំនិតខ្មែរ ហើយ នៅពេលដែលខ្លួន ជួបនឹងទុក្ខវេទនា បង្ខំដោយលទ្ធិថ្មី មិនគិតនាំគ្នាដើបប្រឆាំង បែជានាំគ្នា យល់ឃើញថា ទុក្ខនេះ វាជាកម្មរបស់ខ្លួន ដែលខ្លួនបាន ប្រព្រឹត្តពីអតិតជាតិ។ ក្នុងចិត្តគំនិតនេះ ដែលខ្មែរ ជា ជនរងគ្រោះ មួយនគរ នាំគ្នាទ្រាំរស់ នៅក្នុងរបបខ្មែរ ក្រហម ឥតមានប្រតិកម្មប្រឆាំងអ្វីនោះឡើយ។

អ្វីដែលកើតមានឡើងរឿងៗ នៅស្រុកខ្មែរ ដោយគ្មាន ភាពទំនងសោះ នាំឲយើង លើកយកមកពិនិត្យវាឡើងវិ ញ។ ដូចយ៉ាង ទសន្សៈ ថា ស្រុកខ្មែរ ជាកោះសន្តិភាព នៅ ក្បែរ សង្គ្រាមយៀកណាម ដែលសម្ដេច សីហនុ ផ្ដល់ជូន ដល់ប្រជាពលរដ្ឋ ក៏វាប្រហែល ដូចគ្នានឹង រូបចម្លាក់រំលេច លើផ្ទាំងប្រាសាទអង្គរ : អប្សរា លូអើតឆាយ, ព្រះមហា ក្សត្រដ៏សង្ហា, ប្រជាជន សប្បាយរីករាយ ប្រកបការងារ ដោយងាយស្រួល តែនៅលើផ្ទាំងប្រាសាទ រាប់គីឡូម៉ែត្រ នោះដែរ ក៏បង្ហាញ នូវទិដ្ឋភាព នៃសង្គ្រាមកាចសាហាវ ដែលនាំអោយ អ្នកទស្សនា មានមន្ទិល សួរថា តើ សន្តិ ភាព និង សុភមង្គល នៃប្រជាពលរដ្ឋខ្មែរ នៅសម័យមហា នគរ វាមានធម្មជាតិបែបណា ? ជា ផលា នៃសង្គ្រាម វិបុ ញ្ញ័យ របស់អ្នកដឹកនាំ, ដូច្នេះ លទ្ធិផ្ដាច់ការនិយម នៅ សម័យមហានគរ វាជាឫស នៃរបបដឹកនាំយោធានិយម ហើយទុក ការជំទាស់ នឹងអំណាចអ្នកដឹកនាំ ដ៏មាន បារមីយោធា ជាការប្រមាថ ហើយត្រូវតែ កំទេចវាចោល។

ដូច្នេះចំពោះអ្នកមានគំនិតជំទាស់ មានតែការភៀសខ្លួនទៅរស់នៅប្រទេសជិតខាង ឬ ក្នុងដំបន់ដាច់ស្រយាល ជាទម្រង់ នៃការជំទាស់ តែប៉ុណ្ណោះ។ ហេតុនេះឯង បានជាវាស្ទើរគ្មានសោះឡើយ នៅក្នុងសង្គមខ្មែរ ពីបុព្វ នូវការជំទាស់ទល់មុខ រវាងប្រជាពលរដ្ឋនឹងអ្នកដឹកនាំ។ ដូច្នេះ កោះសន្តិភាព គ្មានសេរីភាពវាគ្រាន់តែជា ការស្រមើស្រមៃ បង្កើតឡើងដោយ របបផ្តាច់ការ សំរាប់រក្សា នូវអំណាចតែប៉ុណ្ណោះ។

## ទំហំ នៃឥទ្ធិពលបរទេស

សួរថា តើ អំពើព្រៃផ្សៃ របស់ ប៉ុល ពត វាមានកំណើតពីការបង្ក្រាបដ៏ហិង្សា របស់សីហនុ, ជាការសងសឹក ទៅលើសង្គមសក្តិភូមិ ? « មែន » នៅលើបន្ទាត់ពេលវេលា : ការបង្ក្រាបដ៏ព្រៃផ្សៃ របស់សីហនុ ទៅលើអ្នកប្រឆាំង វាជម្រុញ ប៉ុល ពត ឲចូលព្រៃ ដើម្បី ប្រឆាំងនឹងសីហនុនិយម ដោយយកបដិវត្តន៏ហិង្សា ជាមធ្យោបាយតស៊ូ។ តែមាគ៌ានោះតាមពិត វាមិនមែនជាប្រតិកម្ម កើតមកពី អំពើឃោរឃៅសុទ្ធសាធនោះទេ, ព្រោះវាមានគ្រឹះ ក្នុងមនោគមវិជ្ជា ជា « លំនាំដ៏អស្ចារ្យ » ចេញពី លេនីននិយម ហើយបន្តផ្ទើ ដោយលោក ស្តាលីន, ម៉ៅ និង ហូ ជីមិញ...។ ដូច្នេះ បដិវត្តន៏ហិង្សា របស់ ប៉ុល ពត គឺគ្រាន់តែជាការចម្លងឥតខ្ចោះ ពីគំរូបរទេស តែប៉ុណ្ណោះ។ តែ ពួកអ្នកដឹកនាំកុម្មុយនិស្ត និងពួកឆ្វេងនិយម នៅលើពិភពលោក

ជំទាស់ថា អំពើឃោរឃៅជ្រុល ឬ បដិវត្តន៍ មូលវិវដ្ត (révolution radicale) បែប ប៉ុល ពត ដើម្បី ប្ដូរ សង្គម មិនអាចយក ទ្រឹស្ដីកុម្មុយនិស្ត ពីខាងក្រៅ មកពន្យល់វា បាននោះឡើយ ព្រោះថា វាមិនដែលមានបែបនេះសោះឡើយ។ ទស្សនៈនេះ វាជា ការកំសាកមួយតែប៉ុណ្ណោះ ព្រោះ ចំនួន នៃជនរងគ្រោះ ពីសំណាក់ លទ្ធិកុម្មុយនិស្ត នៅលើ ពិភពលោក ប្រមាណ ១០០ លាននាក់ វាបញ្ជាក់ នូវការ អនុវត្ត នៃភេរវកម្ម ជាមូលវិវដ្ត របស់អង្គការលើ វាគ្មាន អ្វីខុសគ្នានឹង គោលវិធី របស់ ស្តាលីន, ម៉ៅ និង ហូ ជីមិញ នោះឡើយ។ តើអាចនិយាយបានថា ទ្រឹស្ដី កុម្មុយនិស្ត វា គ្មានកំហុសអ្វីនោះឡើយ ដោយប្រៀបធៀបទៅនឹង ការ អនុវត្តន៍ របស់ខ្លួន ? ការបារម្ភ និង របៀបសិក្សា បែប នេះ តើវានៅអាចគាំទ្របានទៀត ថា លទ្ធិកុម្មុយនិស្ត ពិត ឬ ការមនុវត្តិន៍ទ្រឹស្ដី និង លទ្ធិកុម្មុយនិស្ត គតិបណ្ឌិត វា មិនដូចគ្នាជាដាច់ខាត ? គំនិត បែបនេះ ក៏ដូចជាយល់ ឃើញ ថា ទ្រឹស្ដី ណាស៊ី និង នយោបាយ Hilter វាខុសគ្នា នោះដែរ។

## ឥទ្ធិពលបារាំង

ពួកអ្នកដឹកនាំ ខ្មែរក្រហម ស្ទើរទាំងអស់ ជានិស្សិតនៅ ប្រទេសបារាំង ហើយមួយចំនួន បានចូលជា សមាជិក នៃ

គណបក្សកុម្មុយនិស្តបារាំងសែស រួមទាំង ប៉ុល ពត។ ពួកនោះ ទុកលោក M. Robespierre (១៧៥៨-១៧៩៤), អ្នកបដិវត្តន៍បារាំង ដ៏ល្បីមួយ នៅសតវត្សទី១៨, ជាវិរបុរសរបស់គេ។ កម្មាភិបាលខ្មែរក្រហមម្នាក់ ដែលជាអតិតនិស្សិតខ្មែរនៅស្រុកបារាំង និយាយថា ចំណុចរួម នៃ ប៉ុល ពត និង Robespierre គឺ សេចក្តីប្តេជ្ញាចិត្ត និង ភាពសុចរិតបំផុត។ តែ ពួកបញ្ញវន្តបារាំងសែស គេពន្យល់ថា វាគ្មានឃើញមាន ស្នាមអ្វីឡើយ នៅក្នុងបដិវត្តន៍បារាំង ដែលអាចយកទៅប្រដូចនឹង បដិវត្តន៍ របស់ ប៉ុល ពត។ តែនៅពេល ប៉ុល ពត បិទទ្វារស្រុកខ្មែរ ដើម្បី សម្លាប់ប្រជាពលរដ្ឋខ្មែរ ក្នុងនាម កុម្មុយនិស្ត ពួកអ្នកបញ្ញវន្តបារាំងឆ្វេងនិយម នៅស្ងៀម ហើយនៅតែបន្ត កោតសរសើរ ដល់ ម៉ៅ និង ហូ ជីមិញ។

## ឥទ្ធិពល កុម្មុនិស្តអាស៊ី: យួន-កូរ៉េខាងជើង និង ចិន

## ពីយួន :

គណបក្សកុម្មុយនិស្តខ្មែរ (គ.ក.ខ.) ជាដំបូង វាគ្រាន់តែជាផ្នែកមួយ នៃគណបក្សកុម្មុនិស្ត ឥណ្ឌូចិន ដែលមានយួនជាអ្នកត្រួតត្រា។ ហើយបន្ទាប់មក យួន គេបំបែកជាបីមែកជាតិ : យួន-ខ្មែរ-លាវ តែស្ថិតនៅក្រោមឥទ្ធិពលយួនដដែល។ ទើបដល់ឆ្នាំ ១៩៦០ បានមានបែកចេញដាច់ពីយួន គ្រាន់តែជាទ្រឹស្តីប៉ុណ្ណោះ ព្រោះពួកខ្មែរក្រហម ត្រូវការ

ជំនួយយួន នៅក្នុង បរិបទ នយោបាយ និង ភូមិសាស្ត្រ សង្គ្រាម នៅយៀកណាម។ ឆ្នាំ១៩៧០ ផ្តើមសង្គ្រាម នៅស្រុកខ្មែរ, គ.ក.ខ. នៅក្នុង បរិបទខាងលើនេះ គ្មានស្វ័យភាព នៅក្នុងសមរភូមិឡើយ។ យុទ្ធសាស្ត្រ និង កលយុទ្ធសឹក គឺទ័ពយួនកុម្មុយនិស្ត គេជារៀបចំទាំងអស់។ តួនាទី របស់ គ.ក.ខ. គឺសំរាប់តែ ធ្វើសម្ពាធនយោបាយទៅលើសម្តេច សីហនុ អោយបន្តគាំទ្រយួនកុម្មុយនិស្ត តែប៉ុណ្ណោះ។ ចាប់ពីឆ្នាំ ១៩៧៣ នៅក្នុងក្របខណ្ឌ កិច្ចព្រមព្រៀងសន្តិភាព ឆ្នាំ ១៩៧៣, ប៉េកាំង, នៅចំពោះមុខហាណូយ ធ្វើពុតជាអ្នកប្រឆាំងនឹងគំនិតនេះ, ជំរុញ ពួកខ្មែរក្រហម ឲបដិសេធ នូវកិច្ចព្រមព្រៀងសន្តិភាព ដោយយកលេសថា ជាឧបសគ្គ នៃដំណើរបដិវត្តន៏។ ពួកអ្នកវិភាគនយោបាយ លោកខាងលិច យកចំណុចនេះ ជាការពិត ហើយ នាំគ្នាជឿជាក់ថា ពួកខ្មែរក្រហម និង យួនកុម្មុយនិស្ត ឈ្លោះគ្នា លើចំណុចនេះ។ ពួកអ្នកវិភាគទាំងនោះ នាំគ្នាចាញ់បោកល្បិចយួន ដូចសព្វដង។ តាមពិតហាណូយ គ្មានបំណងចង់អោយពួកខ្មែរ ទទួលស្គាល់ នូវកិច្ចព្រមព្រៀងសន្តិភាពនោះឡើយ ព្រោះថា បើពួកខ្មែរយល់ព្រម យកមក អនុវត្ត គឺទ័ពយួនកុម្មុយនិស្ត នឹងជួបនូវការពិបាក បន្តស្ថិតនៅក្នុងស្រុកខ្មែរ ព្រោះវានឹងអាចមាន សាមគ្គីភាព រវាងខ្មែរនិងខ្មែរ គ្រប់និន្នាការនយោបាយ ដើម្បី ការពារបូរណភាពទឹកដីខ្មែរ ដែលផ្ទុយ

ពីប្រយោជន៍យួន ដែលគេ ត្រូវការជាចាំបាច់ទឹកដីខ្មែរ សំរាប់គាំទ្រ នូវការបន្តធ្វើសង្គ្រាម ក្រោយពី ការចុះហត្ថលេខា សន្តិភាព ជាមួយ សហរដ្ឋអាមេរិក។ ការបដិសេធនៃពួកខ្មែរក្រហម ផ្តល់ នូវលទ្ធភាពនេះ អោយគេ ហើយគ្មាននរណាមួយ អាចចោទប្រកាន់គេបានថា គេនៅពីក្រោយ នូវការបដិសេធនោះ។ ក្នុងកលល្បិចនេះ មិនថាតែ គ.ក.ខ. សូម្បីតែ ប៉េកាំង និង អាមេរិកាំង ក៏ចាញ់បោក ហាណូយដែរ : គោលដៅទីបំផុត របស់ហាណូយ គឺជ័យជំនិះលើយួនខាងត្បូង ដោយកាណុងពីព្រោះ ហាណូយមិនចង់ទទួល លទ្ធផល មិនពេញលេញ ដូច សន្និសិទ នៅទីក្រុង ហ្សែណែវ នៅឆ្នាំ ១៩៥៤ ម្តងទៀតឡើយ។ តាំងពីឆ្នាំ ១៩៦០ មក, ប៉ុល ពត ទទួលការអប់រំផ្ទាល់ពីយួន, គាត់រស់នៅប្រព័ន្ធយួន, ដូច្នេះ គាត់ មិនអាចយល់ពី កលល្បិចយួនបានឡើយ ព្រោះគាត់ចេះតែសូត្រ រួយមាត់ នូវមេរៀន ដែលយួន បានបង្រៀនគាត់ ហើយវាជ្រាប នៅក្នុងព្រលឹងបដិវត្តន៍ដាច់ខាត របស់គាត់ ដូចយ៉ាង :

១. គំនិតមមៃ នៃការសម្ងាត់ និង ការបិទបាំង[3]។ សាឡុត ស ក៏ដូច ង្វៀង អៃកុក គឺសុទ្ធតែលាក់ខ្លួន នៅក្នុងនាមបដិវត្តន៍ ប៉ុល ពត និង ហូ ជីមិញ។ យៀកកុង វាគ្រាន់តែជាអង្គការ នៅក្រោម ការត្រួតត្រាទាំងអស់ នៃពួកឧត្តម

[3] Obsession du secret et de la dissimulation.

សេនីយ និង កម្មាភិបាលយួនខាងជើង តែប៉ុណ្ណោះ។ ដូច គ្នានៅស្រុកខ្មែរ ពីឆ្នាំ ១៩៧០ ដល់ ១៩៧៣ កងទ័ពយួន កុម្មុយនិស្ត លាក់ខ្លួននៅក្នុង រណសិរ្សបង្រួបបង្រួមជាតិ ហើយវាយប្រហារកងទ័ពជាតិខ្មែរ។

២. ការប្រើ រណសិរ្សរួម ដើម្បីពង្រីក ការតស៊ូនៅគ្រប់ទី កន្លែង និង គ្រប់មជ្ឈដ្ឋាន ដូចយ៉ាង លោក ហូ ជីមិញ ទទួលយក ព្រះថៅ បៅ ដាយ ជាទីប្រឹក្សា អស់មួយរយៈ។ ឧទាហរណ៍ : ការបង្កើត រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិ នៅឆ្នាំ ១៩៧០ គឺយកតាម យុទ្ធសាស្ត្រ រណសិរ្សរួម របស់ យួននោះឯង។ សម្តេច សីហនុ ជាប្រមុខរាជរដ្ឋាភិបាល តែឈ្មោះ តែពួកអ្នកសម្រេចកិច្ចការ គឺ ប៉ែកាំង និង ហា ណូយ។

៣. ការប្រើលទ្ធិកុម្មុនិស្ត ជាលទ្ធិសង្គ្រាម នៅក្នុងបរិបទ នៃជម្លោះយោធា។ កងទ័ពជា ឆ្អឹងខ្នង រហូតដល់ ភារៈ អាស្រ័យហេតុ[4] នៃរបបដឹកនាំតែម្តង ហើយនៅពេល ជាមួយគ្នា កងទ័ព ផ្តល់ នូវគំរូ នៃការប្រមូលប្រជាជន ជា កំណែន បញ្ចូលក្នុងការតស៊ូប្រដាប់អាវុធ និង ជាគំរូសេដ្ឋ កិច្ចសង្គ្រាម ដល់ប្រជាពលរដ្ឋ។ នៅក្នុងគំរូនេះឯង ដែល អង្គការលើ ទុកកងទ័ពខ្លួន ជា កម្លាំងមុខ នៃបដិវត្តន៍។

[4] Raison d’être.

## ពីកូរ៉េខាងជើង :

ប៉ុល ពត ធ្លាប់បានធ្វើទស្សនកិច្ច នៅកូរ៉េខាងជើង ក្នុងឋានៈជានាយករដ្ឋមន្ត្រី។ នៅក្នុង កម្ពុជាប្រជាធិបតេយ្យ មាន អ្នកបច្ចេកទេសកូរ៉េជាច្រើន មកជួយរៀបចំបង្កើតឧស្សាហកម្ម។ ក្នុង ទស្សនកិច្ច នៅទីក្រុងព្យុងយ៉ាង ប៉ុល ពត ច្បាស់ជាមានការរំភើប នូវសណ្ដាប់ធ្នាប់ នៃការរស់នៅ របស់ប្រជាជនកូរ៉េ បែបនៅក្នុងបន្ទាយយោធា។ ចំពោះគាត់ « គីមអ៊ីលស៊ុងនិយម » គឺ ការបោសសំអាតសត្រូវនយោបាយ ជាអចិន្ត្រៃ លុះត្រាតែគ្មានសល់មួយក្បាល។ សកម្មភាព ចារកិច្ច នៅក្នុងមហាជន នៃប៉ូលីសបក្សគឺជានយោបាយសន្តិសុខជាតិ ដើម្បី បោចខ្លាំងសង្គមចោល។ ដូច្នេះ ការប្រយុទ្ធ នៃវណ្ណៈ វាមិនជាការចាំបាច់នោះឡើយ ព្រោះនៅក្នុងសង្គមស្អាតល្អ វាគ្មានវណ្ណៈ គឺថាមានតែ បក្ស-រដ្ឋ (Parti-Etat) ដែលជាអ្នកដឹកនាំ នៅក្រោម បញ្ញាភ្លឺថ្លា របស់លោក គីម អ៊ីលស៊ុង ដែលជាបិតាជាតិ។ ចំណុចទាំងនោះឯង ដែល ប៉ុល ពត យកមកអនុវត្ត ឥតខ្ចោះនៅស្រុកខ្មែរ។

## ពីបងធំ ចិន

ចាប់ពីឆ្នាំ ១៩៧៣, ប៉េកាំង ចាប់ផ្ដើមលូកដៃជ្រៅមកក្នុងសមរភូមិ នៅស្រុកខ្មែរ ដើម្បី រៀបចំទុកជាមុន បន្ទាប់ពីការដួលរលំ អាចស្មានបាន នៃរបបសាធារណរដ្ឋខ្មែរ គ្មាន

ជំនួយអាមេរិកាំង។ ចិន ត្រូវការ គ.ក.ខ. ដឹកនាំស្រុកខ្មែរ គ្មានសីហនុ ព្រោះ សីហនុ ជាមនុស្ស ហួសសម័យ មិនអាច ដឹកនាំ បដិវត្តន៍មូលវិវដ្ត ក្រោយពីចប់សង្គ្រាមបាននោះ ឡើយ។ ចំពោះ គ.ក.ខ. ជម្រើសយកចិន គឺជា របង ការពារដែនដីខ្មែរ ប្រទល់នឹងយួនកុម្មុយនិស្ត។ បន្ទាប់ពី ជ័យជំនះ នៅឆ្នាំ ១៩៧៥, អ្នកបច្ចេកទេសចិន ប្រមាណ ៤ ពាន់នាក់ បានមកដល់ភ្នំពេញ ដើម្បី ជួយរៀបចំស្រុក ខ្មែរឡើងវិញ នៅលើមូលដ្ឋាន យកជនបទ ធ្វើជា សមូហ ភាព តាមការពិសោធ របស់ចិន។ បើគេយក ការរៀបចំ នោះមកពិនិត្យ គឺវាដូចគ្នាបេះបិទនឹង ផែនការចិន នៅ ឆ្នាំ ១៩៥៨ : អាហារដ្ឋានចាំបាច់, ប្រមូលផ្តុំកុមារាកុមារី នៅក្នុងមជ្ឈមណ្ឌលអប់រំបក្ស, សមូហភាវកម្ម នៃវត្ថុប្រើ ប្រាស់, មហាការដ្ឋាន ធារាសាស្ត្រ ដែលត្រូវការចាំបាច់ នូវ អ្នកធ្វើការច្រើនក្រៃ, កំរិតពេលវេលាធ្វើឲសម្រេចយ៉ាងខ្លី បំផុត សំរាប់គម្រោងនិមួយៗ។ នៅឆ្នាំ ១៩៥៨ ម៉ៅ និយាយថា « ជាមួយ គ្រាប់ធញ្ញជាតិ និង ដែក, អ្វីក៏អាច ធ្វើបានទាំងអស់ »។ តែ ផែនការ មហាលោតផ្លោះ របស់ ម៉ៅ នោះ នាំបង្កើត ទុរ្ភិក្ស នៅស្រុកចិន ដែល ប៉ុល ពត មិនបានយកវាមកពិចារណា។

# សេចក្តីសន្និដ្ឋាន

អ្វីដែល អង្គការខ្មែរក្រហម យកមកអនុវត្ត នៅស្រុកខ្មែរ តាមពិត គឺជាការចម្លងសុទ្ធសាធ ពីបរទេស ជាពិសេសពីគំរូ របស់កុម្មុយនិស្តអាស៊ី មាន ចិន, យួន និង កូរ៉េខាងជើង។ ក្រោយបីឆ្នាំ នៃជ័យជំនះ ពួកខ្មែរក្រហម, អ្នកកាសែតបរទេសម្នាក់ បានសួរសំនួរទៅ ប៉ុល ពត ថា : « អ្វីទៅដែលជា សមិទ្ធិកម្មសំខាន់ របស់កម្ពុជាប្រជាប្រធិបតេយ្យ ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ ? » ចម្លើយរបស់គាត់គឺ : « សមិទ្ធិកម្មសំខាន់គឺ បានកំទិចពួក ដែលមានបំណងក្បត់ និង គ្រប់អំពើជ្រៀតជ្រែក, វិច្ឆេទកម្ម, គោលបំណងធ្វើរដ្ឋប្រហារ និង ទង្វើឈ្លានពាន ពីសំណាក់សត្រូវគ្រប់ផុន »

នៅក្នុងចម្លើយនេះ គេឃើញថា អ្វីជាខ្មែរ គឺ ខ្មែរសម្លាប់ខ្មែរ ស្ទើរអស់មួយនគរ តាមក្បួនបរទេស។ មោទនភាពរបស់ ប៉ុល ពត គឺបាន ធ្វើឃាតកម្មមហាជន ដើម្បីសាងសង្គម អោយបានល្អជាង នូវការចង់បាន របស់ លោក ស្តាលីន និង ម៉ៅ សេងទុង។ តែ មាតុភូមិ ដែល ប៉ុល ពត ស្រម័យចង់បាន គឺ មានរូបភាព ជា ម្តាយចុង ដ៏កំណាចសម្លាប់កូនឯង។ ការណ៏នេះឯង ជា ភាពខុសគ្នា រវាងគំនិតហួសវិស័យ របស់ ប៉ុល ពត នឹង លទ្ធផលដ៏អាក្រក់បំផុត ដែលប្រជាពលរដ្ឋខ្មែរ ទទួលរង។

ចម្លើយនឹង សំនួរ ថា « ហេតុអ្វី សម្លាប់ ? » គឺ ភាពខ្វាក់, តម្រេបក្សពួក, សិតិវិបល្លាសស្ទ័គ្រចិត្ត របស់ គ.ក.ខ. ដែលដឹកនាំដោយ មនុស្សមួយក្តាប់ ទទួល ការអប់រំពីបរទេស និងឥទ្ធិពលកុម្មុយនិស្ត ហើយយកវាមក អនុវត្តទាំងមូល ដើម្បី បំរើ នូវគំនិតហួសហេតុ របស់ខ្លួន។ តែការសម្លាប់សត្រូវ វាមិនមែនជា របៀបថ្មី ដែល អង្គការលើបានបង្កើតឡើងនោះទេ។ គេឃើញមាន នៅក្នុង លទ្ធិព្រះយេស៊ូ (Evangile) បានអនុម័តថា « អ្នកណាមិនស័គ្រនឹងខ្ញុំ គឺជាអ្នកប្រឆាំងនឹងខ្ញុំ »។ តែលោក លេនីន គាត់បង្កើតគំនិតថ្មី ដោយបន្ថែមថា « អ្នកណាមិនស័គ្រនឹងខ្ញុំ គឺជាអ្នកប្រឆាំងនឹងខ្ញុំ - តែអ្នកប្រឆាំងនឹងខ្ញុំ ត្រូវតែស្លាប់ »ហើយគំនិតនេះ ត្រូវបាន ពួកជនកុម្មុយនិស្តនៅលើពិភពលោក យកមកអនុវត្ត ជានយោបាយទូទៅ នៅក្នុងសង្គម។ ចំពោះ អង្គការកុម្មុយនិស្ត គេទុកអ្នកប្រឆាំង ជា សត្រូវ បន្ទាប់មក ជា ឧក្រិដ្ឋជន ដែលត្រូវតែដកចេញជាដាច់ខាត។ ការដកចេញនេះ វាស្មើរតែជាយន្តនាំទៅរកគំនិត នៃការសម្លាប់រង្គាល ព្រោះថា តទៅមុខទៀត វាចារវិទ្យា របស់សមស្ថនិយម មិត្ត/សត្រូវ វាមិនគ្រប់គ្រាន់ សំរាប់ដោះស្រាយបញ្ហា ជាសារវន្ត នេះឡើយ : ការស្វែងរក នៃមនុស្សជាតិ រួមឡើងវិញ, បរិសុទ្ធ, គ្មានសត្រូវ តាមទំហំ ព្រះមេស្ស៊ី (dimension messianique) នៃគំរោងម៉ាក្សស៊ីស គឺជា បេសកកម្ម ធ្វើដោយ និង ដើម្បី វណ្ណៈពល

ជីព។ គំរោងនេះ ធ្វើអោយមើលឃើញត្រូវ នូវវិធី បង្រួប បង្រួម មនុស្សជាតិ តាមកម្លាំង ក្នុងបក្ស, ក្នុងសង្គម, ក្នុង ប្រទេស នៅទីបញ្ចប់ ក្នុង សាកលោក ដែលជាវិធី ជជុះចោលដូចសំរាម ចំពោះអ្នកណា ដែលមិនចូលមក ក្នុង ការសម្រាំងនេះ។ ដូច្នេះ ពី ភាពសមហេតុផល (logique) នៃការតស៊ូនយោបាយ, ពួកកុម្មុយនិស្ត នាំគ្នា រំកិលទៅរក ភាពសមហេតុផល នៃការជម្រុសចោល, បន្ទាប់មក ទៅរក មនោគមវិជ្ជា ពិឃាតនិយម ហើយនៅ ទីបំផុត គឺ ទៅរក ការសម្លាប់រង្គាលសត្រូវ និង ការកំទិច ចោលអោយអស់ នៃវត្ថុធាតុ មិនបរិសុទ្ធ។ នៅក្នុង ភាព សមហេតុផលនេះឯង ដែល អង្គការលើ បានសម្លាប់ខ្មែរ ដោយយល់ថា ប្រជាពលរដ្ឋខ្មែរ វារលួយអស់ទៅហើយ ដូច្នេះ ត្រូវសម្លាប់មនុស្សស្អុយ ដែលជា សត្រូវលាក់ខ្លួន នៅក្នុងសង្គមសក្តិភូមិ។ ដើម្បី កសាងកម្ពុជាថ្មី ត្រូវតែប្តូរ ប្រជាពលរដ្ឋ តាមការសម្រាង ដកចេញ វត្ថុធាតុ មិន បរិសុទ្ធ។ ចំពោះ អង្គការលើ មនុស្សខ្មែរ វាគ្រាន់តែជា វត្ថុ ស្អុយ ដែលត្រូវតែកំទិចចោល តែប៉ុណ្ណោះ៕